ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៧១ អនក្រ.បក

# អនុក្រឹត្យ
# ស្ដីពី
# ការរៀបចំ និង ការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលបណ្ដុះធុរកិច្ចថ្មី "តេជោ"

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៣ ស្ដីពីការបង្កើតមជ្ឈមណ្ឌលបណ្ដុះធុរកិច្ចថ្មី "តេជោ" ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់ពីការរៀបចំ និង ការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" សរសេរជាអក្សរកាត់ថា "**ម.ធ.ត.**" ។

**មាត្រា២.-**

**ម.ធ.ត.** មានរូបនិមិត្តសញ្ញា និង ត្រាដោយឡែក ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។

រូបនិមិត្តសញ្ញា និង ត្រា របស់ **ម.ធ.ត.** ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យនេះ។

## ជំពូកទី ២
## រចនាសម្ព័ន្ធ

**មាត្រា៣.-**

**ម.ធ.ត.** មានរចនាសម្ព័ន្ធដូចខាងក្រោម៖

- នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ
- នាយកដ្ឋានអភិវឌ្ឍធុរកិច្ចថ្មី
- នាយកដ្ឋានបច្ចេកវិទ្យា និង នវានុវត្តន៍
- នាយកដ្ឋានបរិវត្តកម្មឌីជីថលសហគ្រាស

នាយកដ្ឋាននីមួយៗនៃ **ម.ធ.ត.** មានការិយាល័យក្រោមឱវាទមួយចំនួនតាមការចាំបាច់។ ការរៀបចំ និង ការប្រព្រឹត្តទៅនៃការិយាល័យក្រោមឱវាទនាយកដ្ឋាននីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

នាយកដ្ឋាននីមួយៗត្រូវដឹកនាំដោយប្រធាន ១(មួយ)រូប ដែលត្រូវតែងតាំងដោយអនុក្រឹត្យ និង មានអនុប្រធានមួយចំនួនជាជំនួយការ ដែលត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ **ម.ធ.ត.**។

អង្គការលេខនៃ **ម.ធ.ត.** ត្រូវបានកំណត់ជាឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យនេះ។

**មាត្រា៤.-**

នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុបំពេញមុខងារជាសេនាធិការឱ្យ **ម.ធ.ត.** លើការងារគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និង បុគ្គលិក ដោយមានភារកិច្ចដូចខាងក្រោម៖

- ជាលេខាធិការដ្ឋានប្រកចេញ-ចូល និង ជាកន្លែងតម្កល់ឯកសារនិងលិខិតស្នាមរបស់ **ម.ធ.ត.**
- រៀបចំគម្រោងថវិកា និង ផែនការលទ្ធកម្មប្រចាំឆ្នាំ ព្រមទាំងអនុវត្តថវិកា និង កិច្ចលទ្ធកម្ម
- គ្រប់គ្រង និង តាមដានចំណូលចំណាយ
- រៀបចំ សម្របសម្រួល និង អនុវត្តផែនការ អប់រំ បណ្តុះបណ្តាល និង គ្រប់គ្រងបុគ្គលិក

- រៀបចំរបាយការណ៍នៃការគ្រប់គ្រងបុគ្គលិក របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និង របាយការណ៍លទ្ធកម្ម
- រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាល និង របាយការណ៍វឌ្ឍនភាពការងារ និង សមិទ្ធកម្ម និង របាយការណ៍ពាក់ព័ន្ធនានា
- ទំនាក់ទំនង និង សម្របសម្រួលកិច្ចសហការជាមួយស្ថាប័នជាតិ និង អន្តរជាតិ និង វិស័យឯកជនក្នុងការគាំទ្រការងាររបស់ **ម.ធ.ឥ.**
- សម្របសម្រួលរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា កិច្ចប្រជុំ និង កម្មវិធីនានា
- ជាលេខាធិការនៃគណៈកម្មការរៀបចំបញ្ជីសារពើភណ្ឌ និង
- បំពេញតួនាទី និង ភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីនាយក **ម.ធ.ឥ.**។

**មាត្រា៥.-**

នាយកដ្ឋានអភិវឌ្ឍធុរកិច្ចថ្មីបំពេញមុខងារជាសេនាធិការឱ្យ **ម.ធ.ឥ.** លើការងារអនុវត្តកម្មវិធីជំរុញ គាំទ្រ និង អភិវឌ្ឍធុរកិច្ចថ្មី និង កម្មវិធីអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មី ដោយមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ជំរុញ គាំទ្រ និង អភិវឌ្ឍធុរកិច្ចថ្មី
- រៀបចំ និង អនុវត្តកម្មវិធី និង ផ្តល់សេវានានា ដើម្បីជំរុញ គាំទ្រ និង អភិវឌ្ឍធុរកិច្ចថ្មី
- ចូលរួមអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មីនៅកម្ពុជា និង ចូលរួមតភ្ជាប់ប្រព័ន្ធនេះទៅកាន់ប្រព័ន្ធស្រដៀងគ្នាក្នុងតំបន់ និង សកល
- រៀបចំ និង ប្រតិបត្តិថ្នាលបច្ចេកវិទ្យាឌីជីថលសម្រាប់ផ្តល់ព័ត៌មាន ជំរុញ គាំទ្រ និង អភិវឌ្ឍធុរកិច្ចថ្មី និង សម្រាប់ចូលរួមអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មី
- ប្រមូលជាតុចូល និង ចងក្រងឯកសារនានាពាក់ព័ន្ធនឹងការជំរុញ គាំទ្រ និង អភិវឌ្ឍធុរកិច្ចថ្មី និង ពាក់ព័ន្ធនឹងការចូលរួមអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មី
- សហការជាមួយស្ថាប័នជាតិ និង អន្តរជាតិពាក់ព័ន្ធនានាក្នុងការជំរុញ គាំទ្រ និង អភិវឌ្ឍធុរកិច្ចថ្មី និង ការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មី និង
- បំពេញតួនាទី និង ភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីនាយក **ម.ធ.ឥ.** ។

**មាត្រា៦.-**

នាយកដ្ឋានបច្ចេកវិទ្យា និង នវានុវត្តន៍បំពេញមុខងារជាសេនាធិការឱ្យ **ម.ធ.ឥ.** លើការងារស្រាវជ្រាវកេនវានុវត្តន៍ ព្រមទាំងអភិវឌ្ឍ និង ប្រតិបត្តិថ្នាលឌីជីថលគ្រឹះ និង គាំទ្រដល់សេវាចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដោយមានភារកិច្ចដូចខាងក្រោម៖

- រៀបចំអភិវឌ្ឍ និង គ្រប់គ្រងថ្នាលឌីជីថលគ្រឹះ ដើម្បីជំរុញសហបង្កើតថ្មី និង នវានុវត្តន៍ដល់ការអភិវឌ្ឍធុរកិច្ចថ្មី និង ធុរកិច្ចឌីជីថល

- ស្វែងរកនវានុវត្តន៍ រៀបចំ និង អភិវឌ្ឍថ្នាលបច្ចេកវិទ្យាឌីជីថលសម្រាប់ជំរុញ គាំទ្រ និង អភិវឌ្ឍធុរកិច្ចថ្មី និង សម្រាប់ចូលរួមអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មី ថ្នាលបច្ចេកវិទ្យាឌីជីថល និង បរិវត្តកម្មឌីជីថល
- ផ្តល់សេវាប្រឹក្សាយោបល់ និង បច្ចេកទេសនៃការអភិវឌ្ឍគំរូផលិតផលដល់ស្ថាបនិកធុរកិច្ចថ្មី
- ស្រាវជ្រាវបែបអនុវត្តន៍សម្រាប់រកនវានុវត្តន៍ ក្នុងការដោះស្រាយបញ្ហាគន្លឹះនានាក្នុងធុរកិច្ចថ្មី ធុរកិច្ចឌីជីថល និង សេដ្ឋកិច្ចឌីជីថល
- ផ្តល់កម្មសិក្សាដល់សិស្ស និស្សិត ដើម្បីរួមចំណែកក្នុងការកសាងជំនាញ និង ធនធានមនុស្សឌីជីថល
- សហការជាមួយស្ថាប័នជាតិ និង អន្តរជាតិពាក់ព័ន្ធនានាសំដៅជំរុញនវានុវត្តន៍ ការផ្ទេរបច្ចេកវិទ្យា និង ការធ្វើបច្ចុប្បន្នកម្មនៃបច្ចេកវិទ្យាថ្មីៗ និង
- បំពេញតួនាទី និង ភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីនាយក **ម.ឆ.ត.** ។

**មាត្រា៧**.-

នាយកដ្ឋានបរិវត្តកម្មឌីជីថលសហគ្រាសបំពេញមុខងារជាសេនាធិការឱ្យ **ម.ឆ.ត.** លើការងារអនុវត្តកម្មវិធី ចងក្រងឯកសារ និង ស្រាវជ្រាវគោលនយោបាយពាក់ព័ន្ធនឹងការជំរុញការចាប់យកឌីជីថលរបស់សហគ្រាស ដោយមានភារកិច្ចដូចខាងក្រោម៖

- អនុវត្តកម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាស
- រៀបចំ អភិវឌ្ឍ និង អនុវត្តផែនការស្រាវជ្រាវនានា ដែលបម្រើដល់ការគាំទ្រ បណ្តុះបណ្តាល និង ជំរុញការចាប់យកឌីជីថលរបស់សហគ្រាស
- រៀបចំកម្មវិធី និង សកម្មភាពដើម្បីផ្តល់ព័ត៌មាន និង បណ្តុះបណ្តាលការចាប់យកឌីជីថលរបស់សហគ្រាស តាមវិស័យ និង តាមកម្រិត
- លើកទឹកចិត្ត និង គាំទ្រការចូលរួមជំរុញ និង ការបណ្តុះបណ្តាលការចាប់យកឌីជីថលរបស់សហគ្រាស
- សិក្សាស្រាវជ្រាវ ប្រមូលទិន្នន័យ និង ជាតុចូល និង ចងក្រងឯកសារនានាពាក់ព័ន្ធនឹងការជំរុញ និង ការបណ្តុះបណ្តាលការចាប់យកឌីជីថលរបស់សហគ្រាស
- សំយោគលទ្ធផលនៃការប្រមូលជាតុចូល និង ការសិក្សាស្រាវជ្រាវ ដើម្បីផ្តល់អនុសាសន៍ជាគោលនយោបាយសំដៅជំរុញ និង បណ្តុះបណ្តាលការចាប់យកឌីជីថលរបស់សហគ្រាស
- ចូលរួមរៀបចំ សម្របសម្រួល និង ជំរុញកិច្ចសហការជាមួយស្ថាប័នជាតិ និងអន្តរជាតិពាក់ព័ន្ធនានាលើការងារស្រាវជ្រាវ បណ្តុះបណ្តាល ផ្ទេរ និង ចែករំលែកចំណេះដឹង បទពិសោធន៍ និង ឧត្តមានុវត្តន៍អន្តរជាតិសំដៅជំរុញការចាប់យកឌីជីថលរបស់សហគ្រាស និង
- បំពេញតួនាទី និង ភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីនាយក **ម.ឆ.ត.** ។

# ជំពូកទី ៣
# អវសានប្បញ្ញត្តិ

**មាត្រា៨.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ២កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី ១ នៃ
## អនុក្រឹត្យលេខ ៥៧១ អនក្រ.បក ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ២០២៣ ស្តីពី
## ការរៀបចំ និង ការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ"

## រូបនិមិត្តសញ្ញារបស់មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ"

- រូបនិមិត្តសញ្ញា មានរាងជារង្វង់ តំណាងឱ្យគោលដៅនៃការបង្កើតធុរកិច្ចថ្មី ដែលសហគ្រិនវ័យក្មេងត្រូវផ្តោតការយកចិត្តទុកដាក់។
- រូបនិមិត្តសញ្ញា មានពណ៌ខៀវ តំណាងឱ្យភាពស្មោះត្រង់ ទំនុកចិត្ត ភាពជឿជាក់ និង ភាពឆ្លាតវៃ។
- សញ្ញាសម្គាល់ផ្សេងៗក្នុងរង្វង់ផ្ទៃពណ៌សនៃផ្ទៃខាងក្រោយ សំដៅលើនវានុវត្តន៍ និង បច្ចេកវិទ្យាឌីជីថលថ្មីៗ ដែលជាវិស័យអាទិភាពរបស់មជ្ឈមណ្ឌលក្នុងការគាំពារ និង បណ្តុះធុរកិច្ចថ្មី។
- រូបនាគ តំណាងឱ្យអ្នកបង្កើតទឹកដីខ្មែរ ដែលប្រៀបបានដូចជាការបង្កើត និង ការបណ្តុះធុរកិច្ចថ្មីៗ។ រូបនាគក៏បង្ហាញពីសហគ្រិនវ័យក្មេង ដែលមានថាមពល សមត្ថភាព និង ឆន្ទៈក្នុងការបង្កើតធុរកិច្ចថ្មី ក្នុងបរិបទបច្ចេកវិទ្យាឌីជីថល ផ្សារភ្ជាប់ទៅនឹងការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល។
- តួខ្លួននាគ មានពីរពណ៌ ដោយផ្នែកកន្ទុយមានពណ៌ស្រាលជាងដងខ្លួន សំដៅដល់ការតភ្ជាប់ និង ទំនាក់ទំនងនៃមនុស្ស និង បច្ចេកវិទ្យា ដែលបង្កើតបានជាប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មី និង សំដៅដល់ដំណាក់កាលលូតលាស់ជំពាក់ដោគជ័យរបស់ធុរកិច្ចថ្មី។

ត្រារបស់មជ្ឈមណ្ឌលបណ្ដុះធុរកិច្ចថ្មី "តេជោ"

## ឧបសម្ព័ន្ធទី ២ នៃ
## អនុក្រឹត្យលេខ២៧១ អនក្រ.បក............... ចុះថ្ងៃទី..១៨... ខែ.សីហា... ឆ្នាំ២០២៣ ស្ដីពី
## ការរៀបចំ និង ការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលបណ្ដុះធុរកិច្ចថ្មី "តេជោ"

## អង្គការលេខនៃមជ្ឈមណ្ឌលបណ្ដុះធុរកិច្ចថ្មី "តេជោ"

